ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦៦២១ សជណ.កសក.ប

# សេចក្តីជូនដំណឹង
## ស្តីពីការប្រឡងជ្រើសរើសចូលបម្រើការងារ
## ក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

តាមលិខិតលេខ ៦៤៦ ស.ជ.ណ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ លេខ ១០៥៤ ស.ជ.ណ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីផែនការ ក្របខណ្ឌឆ្នាំ២០១១ សម្រាប់ផ្តល់ជូនក្រសួង ស្ថាប័ន ចំណុះរាជរដ្ឋាភិបាល និងលិខិតលេខ ១១៤ មស.ក្រខ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងជាសាធារណៈដល់សិស្ស និងនិស្សិត ទាំងពីរភេទ ឲ្យបានជ្រាបថា ក្នុងឆ្នាំ២០១១នេះ ក្រសួងត្រូវការប្រឡងប្រជែងជ្រើសរើសអ្នកបច្ចេកទេសចំនួន១៣៤នាក់ សម្រាប់បម្រើការងារនៅអង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្មខេត្ត។ បេក្ខជនដែលមានបំណងចូលរួមប្រឡងប្រជែង ត្រូវមានបរិញ្ញាបត្រជំនាញផ្នែក វិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល វិទ្យាសាស្ត្រ រុក្ខកម្ម កសិឧស្សាហកម្ម បច្ចេកវិទ្យា និងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ កៅស៊ូ វិទ្យាសាស្ត្រ គ្រប់គ្រង ព័ត៌មានវិទ្យា នីតិសាស្ត្រ គណនេយ្យ ហិរញ្ញវត្ថុ ឬមានបរិញ្ញាបត្ររង ផ្នែកក្សេត្រសាស្ត្រ ផលិតកម្ម និង បសុព្យាបាល ជលផល រុក្ខកម្ម កសិឧស្សាហកម្ម គ្រឿងយន្តកសិកម្ម និងសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដូចមានតារាងបែងចែកខាងក្រោម ៖

| | ជំនាញ / អង្គភាព | ក្សេត្រសាស្ត្រ | | ផលិតកម្ម និងបសុ | | ជលផល | | រុក្ខកម្ម | | កសិ ឧស្សាហកម្ម | | វិទ្យាសាស្ត្រគ្រប់គ្រង | បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម | មធ្យមវេជ្ជសាស្ត្រ | ព័ត៌មានវិទ្យា | នីតិសាស្ត្រ | សេដ្ឋកិច្ចកសិកម្ម និងអភិ.ជនបទ | | កៅស៊ូ | គណនេយ្យ-ហិរញ្ញវត្ថុ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឧត្តម | មធ្យម | ឧត្តម | មធ្យម | ឧត្តម | មធ្យម | ឧត្តម | មធ្យម | ឧត្តម | មធ្យម | ឧត្តម | ឧត្តម | មធ្យម | ឧត្តម | ឧត្តម | ឧត្តម | មធ្យម | ឧត្តម | ឧត្តម | |
| ក. | *អង្គភាពថ្នាក់កណ្តាល* | *04* | | *02* | | *10* | *05* | *09* | *05* | *02* | | *07* | *02* | *03* | *05* | *05* | *03* | | *04* | *09* | *75* |
| 1 | នាយកដ្ឋានផែនការ និងស្ថិតិ | | | | | | | | | | | 1 | | | | | 1 | | | | *02* |
| 2 | អគ្គនាយកដ្ឋានកសិកម្ម | 2 | | | | | | | | | | | 1 | 3 | | | | | | 2 | *08* |
| 3 | ន.ផលិតកម្ម និងបសុព្យាបាល | | | 1 | | | | | | | | | | | | | | | | 1 | *02* |
| 4 | អគ្គាធិការដ្ឋាន | | | | | | | | | | | 2 | | | | 1 | | | | | *03* |
| 5 | ន.បុគ្គលិក និងអភិ.មនុស្ស | | | | | | | | | | | 2 | | | 1 | | | | | | *03* |
| 6 | រដ្ឋបាលជលផល | | | | | 9 | 5 | | | | | | | | | 1 | | | | 1 | *16* |
| 7 | រដ្ឋបាលព្រៃឈើ | | | | | | | 9 | 5 | | | | | | 1 | 1 | | | | 1 | *17* |
| 8 | អគ្គនាយកដ្ឋានកៅស៊ូ | | | | | | | | | | | | | | | | | | 4 | | *04* |
| 9 | វិទ្យា.អភិ.កសិកម្មកម្ពុជា | 1 | | | | | | | | | | | | | | | | | | 1 | *02* |
| 10 | សាកលវិទ្យា.ភូមិន្ទកសិកម្ម(*) | 1 | | 1 | | | | | | | | | | | | | | | | | *02* |
| 11 | មជ្ឈ.ព័ត៌មាន.ឯកសារកសិកម្ម | | | | | | | | | | | | | | 3 | | | | | | *03* |
| 12 | នាយកដ្ឋានកសិឧស្សាហកម្ម | | | | | | | | | 2 | | | | | | | | | | | *02* |
| 13 | នាយកដ្ឋាននីតិកម្មកសិកម្ម | | | | | | | | | | | | | | | 1 | | | | | *01* |
| 14 | ន.គណនេយ្យ ហិរញ្ញវត្ថុ | | | | | | | | | | | | | | | | | | | 1 | *01* |
| 15 | នាយកដ្ឋានកិច្ចការរដ្ឋបាល | | | | | | | | | | | 2 | | | | 1 | | | | 1 | *04* |
| 16 | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | | | | | | | | | | | | | | | | | | | 1 | *01* |
| 17 | សាលាជាតិកសិកម្មកំពង់ចាម (*) | | | | | 1 | | | | | | | | | | | 1 | | | | *02* |
| 18 | សាលាជាតិកសិកម្មព្រែកលៀប (*) | | | | | | | | | | | | 1 | | | | 1 | | | | *02* |

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh. Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

| ខ. | មន្ទីរកសិកម្មខេត្ត | 15 | 10 | 08 | 10 | | | | | | 06 | | 05 | | | | | 05 | | | 59 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | មន្ទីរកសិកម្មខេត្តតាកែវ | | 1 | 1 | | | | | | | | | | | | | | | | | 02 |
| 2 | មន្ទីរកសិកម្មខេត្តស្វាយរៀង | 1 | | | 1 | | | | | | | | 1 | | | | | | | | 03 |
| 3 | មន្ទីរកសិកម្មខេត្តព្រៃវែង | 1 | | 1 | | | | | | | | | 1 | | | | | | | | 03 |
| 4 | មន្ទីរកសិកម្មខេត្តកំពត | | 1 | | 1 | | | | | | | | | | | | | 1 | | | 03 |
| 5 | មន្ទីរកសិកម្មខេត្តកោះកុង | | 1 | | 1 | | | | | | | | | | | | | 1 | | | 03 |
| 6 | មន្ទីរកសិកម្មខេត្តកំពង់ស្ពឺ | 1 | | 1 | | | | | | | 1 | | | | | | | | | | 03 |
| 7 | មន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង | | 1 | | 1 | | | | | | | | | | | | | | | | 02 |
| 8 | មន្ទីរកសិកម្មខេត្តពោធិ៍សាត់ | | 1 | 1 | | | | | | | 1 | | | | | | | | | | 03 |
| 9 | មន្ទីរកសិកម្មខេត្តបាត់ដំបង | | 1 | | | | | | | | 1 | | 1 | | | | | | | | 03 |
| 10 | មន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ | 1 | | 1 | | | | | | | | | 1 | | | | | | | | 03 |
| 11 | មន្ទីរកសិកម្មខេត្តឧត្តរមានជ័យ | 1 | | | 1 | | | | | | 1 | | | | | | | | | | 03 |
| 12 | មន្ទីរកសិកម្មខេត្តព្រះវិហារ | 1 | | | 1 | | | | | | | | | | | | | | | | 02 |
| 13 | មន្ទីរកសិកម្មខេត្តសៀមរាប | | 1 | | | | | | | | 1 | | | | | | | | | | 02 |
| 14 | មន្ទីរកសិកម្មខេត្តកណ្ដាល | 1 | | | | | | | | | 1 | | | | | | | | | | 02 |
| 15 | មន្ទីរកសិកម្មខេត្តកំពង់ចាម | 1 | 1 | | | | | | | | | | | | | | | | | | 02 |
| 16 | មន្ទីរកសិកម្មខេត្តកំពង់ធំ | 1 | 1 | | | | | | | | | | 1 | | | | | | | | 03 |
| 17 | មន្ទីរកសិកម្មខេត្តស្ទឹងត្រែង | 1 | | | 1 | | | | | | | | | | | | | | | | 02 |
| 18 | មន្ទីរកសិកម្មខេត្តក្រចេះ | 1 | | | 1 | | | | | | | | | | | | | | | | 02 |
| 19 | មន្ទីរកសិកម្មខេត្តរតនគីរី | 1 | | 1 | | | | | | | | | | | | | | 1 | | | 03 |
| 20 | មន្ទីរកសិកម្មខេត្តមណ្ឌលគីរី | 1 | | | 1 | | | | | | | | | | | | | | | | 02 |
| 21 | មន្ទីរកសិកម្មខេត្តកែប | 1 | | 1 | | | | | | | | | | | | | | 1 | | | 03 |
| 22 | មន្ទីរកសិកម្មខេត្តប៉ៃលិន | 1 | | | 1 | | | | | | | | | | | | | | | | 02 |
| 23 | មន្ទីរកសិកម្មខេត្តព្រះសីហនុ | | 1 | 1 | | | | | | | | | | | | | | 1 | | | 03 |
| សរុប (ក+ខ) | | 19 | 10 | 10 | 10 | 10 | 05 | 09 | 05 | 02 | 06 | 07 | 07 | 03 | 05 | 05 | 03 | 05 | 04 | 09 | 134 |

(*) សម្រាប់បេក្ខជនដែលមានបំណងទៅបម្រើការងារនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាជាតិកសិកម្មព្រែកលៀប និងសាលាជាតិកសិកម្មកំពង់ចាម ត្រូវមានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ និងមានបទពិសោធន៍ការងារយ៉ាងតិច ០២ ឆ្នាំ ។

## I. **បែបបទ និងលក្ខខណ្ឌនៃការប្រឡង :**

១. បេក្ខជនទាំងពីរភេទជាសិស្ស និងនិស្សិត ត្រូវ :

- មានបរិញ្ញាបត្រ ការកំណត់អាយុយ៉ាងច្រើនបំផុតត្រឹម ៣០ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មានសញ្ញាបត្រមធ្យមបច្ចេកទេស ការកំណត់អាយុយ៉ាងច្រើនបំផុតត្រឹម ២៥ ឆ្នាំ គិតមកដល់ថ្ងៃប្រឡង
- មិនអនុញ្ញាតចំពោះបេក្ខជនជាមន្ត្រីរាជការ ។

២. ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែមប្រ៍ ចំនួន ០១ ច្បាប់

៣. សញ្ញាបត្រស្របតាមមុខជំនាញដែលប្រឡង ( បើថតចម្លងត្រូវមានការបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ) ចំនួន ០១ ច្បាប់

៤. ជីវប្រវត្តិសង្ខេប មានបិទរូបថត ៤ X ៦ ( សរសេរដោយបេក្ខជនផ្ទាល់ ) ចំនួន ០១ ច្បាប

៥. សាលាកប័ត្រឯកត្តជន ចំនួន ០១ ច្បាប់

៦. រូបថតថ្មី ( ថតចំពីមុខ គ្មានពាក់វ៉ែនតា និងគ្មានពាក់មួក ) ៤ X ៦ ចំនួន ០៣ សន្លឹក

៧. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង ចំនួន ០១ ច្បាប់

៨. បង្កាន់ដៃទទួលពាក្យប្រឡង ចំនួន ០១ ច្បាប់

៩. លិខិតថ្កោលទោស (ត្រូវផ្ដល់រយៈពេល ១៥ថ្ងៃ ក្រោយពេលប្រកាសលទ្ធផលប្រឡងជាប់) ចំនួន ០១ ច្បាប់

## II. **កាលបរិច្ឆេទទទួល និងឈប់ទទួលពាក្យសុំចុះឈ្មោះប្រឡង :**

បេក្ខជនត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ) រាល់ពេលម៉ោងធ្វើការ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី**១៤** ខែ **តុលា** ឆ្នាំ **២០១១** វេលាម៉ោង ១៧ : ៣០ នាទី ជាកាលបរិច្ឆេទចុងក្រោយ នៃថ្ងៃឈប់ទទួលពាក្យ ។

## III. **វិញ្ញាសាប្រឡង ជាវិញ្ញាសាសរសេរ មាន :**

| | | |
|---|---|---|
| ១. វិញ្ញាសាចំណេះដឹងទូទៅ | មេគុណ ១ | រយៈពេល ១ ម៉ោង ៣០ នាទី |
| ២. វិញ្ញាសាជំនាញបច្ចេកទេស | មេគុណ ២ | រយៈពេល ២ ម៉ោង |
| ៣. វិញ្ញាសាភាសាអង់គ្លេស | មេគុណ ១ | រយៈពេល ១ ម៉ោង ៣០ នាទី |

IV. **ទីកន្លែងប្រឡង និងមណ្ឌលប្រឡង** :

- មណ្ឌលប្រឡង : សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សម័យប្រឡង : ក្រសួងនឹងជូនដំណឹងនៅពេលក្រោយ ។

ចំពោះព័ត៌មានផ្សេងៗទៀត បេក្ខជនអាចទាក់ទង នៅនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀងរាល់ម៉ោងធ្វើការ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ០៣ ឆ្នាំ២០១១*

**រដ្ឋមន្ត្រី**

ច័ន្ទ សារុន

**ចម្លងជូន:**

- *ទីស្តីការ គណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល*
  "**ដើម្បីជូនជ្រាប**"
- *គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*
  "**ដើម្បីជ្រាប និងផ្សព្វផ្សាយ**"
- *អគ្គនាយកវិទ្យុ និងទូរទស្សន៍ជាតិកម្ពុជា*
  "**ដើម្បីជួយសម្រួលផ្សព្វផ្សាយ**"
- *ឯកសារ - កាលប្បវត្តិ*